# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

លេខ ..................... រ.ស.

## សូមជម្រាបជូន
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**តាមរយៈ** : សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា

**កម្មវត្ថុ** : ការស្នើសុំពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា អោយប្រទេសហត្ថលេខី អនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ ។

**យោង** : _មាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
_កិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីកម្ពុជា ឆ្នាំ១៩៩១
_លិខិតរបស់ឯកឧត្តម សម រង្ស៊ី ផ្ញើជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំជាអ្នកតំណាងរាស្ត្រ ដូចមានរាយនាមខាងក្រោម សូមសួរទៅរាជរដ្ឋាភិបាលថា តើហេតុអ្វីបានជារាជរដ្ឋាភិបាលមិនទាន់បានស្នើសុំឲ្យសហគមន៍អន្តរជាតិ ជាពិសេសប្រទេសជាហត្ថលេខីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីកម្ពុជា ឆ្នាំ១៩៩១ អនុវត្តកិច្ចព្រមព្រៀងនេះជាបន្ទាន់យ៉ាងត្រឹមត្រូវ និងពេញលេញ ក្នុងខណៈដែលប្រទេសកម្ពុជាកំពុងតែប្រឈមមុខការឈ្លានពានពីសំណាក់ប្រទេសថៃ ?

យើងខ្ញុំសូមរំលឹកថា កិច្ចព្រមព្រៀងទីក្រុងប៉ារីស មិនត្រឹមតែទទួលស្គាល់សិទ្ធិប្រទេសកម្ពុជា ក្នុងការស្នើសុំឲ្យសហគមន៍អន្តរជាតិមកជួយ ពេលណាប្រទេសយើងទទួលរងការគំរាមកំហែង ឬការឈ្លានពានពីប្រទេសណាមួយទៀត តែកិច្ចព្រមព្រៀងនេះបញ្ជាក់ថែមទៀតយ៉ាងច្បាស់ពីកាតព្វកិច្ចនៃប្រទេសជាហត្ថលេខីទាំងអស់ ឲ្យឆ្លើយតបតាមសំណើប្រទេសកម្ពុជា ។ លើសពីនេះទៀត កិច្ចព្រមព្រៀងទីក្រុងប៉ារីសក៏បញ្ជាក់ផងដែរ អំពីយន្តការសម្រាប់អោយសហគមន៍អន្តរជាតិមកជួយប្រទេសកម្ពុជាយ៉ាងពិតប្រាកដ និងឆាប់រហ័ស ។

មាត្រា ៥ នៃកិច្ចព្រមព្រៀង ស្តីពីអធិបតេយ្យភាព ឯករាជ្យភាព បូរណភាពទឹកដី អព្យាក្រឹតភាព និងឯកភាពជាតិនៃកម្ពុជា ចែងជាអាទិ៍ថា :

១_ក្នុងករណីមានការរំលោភ ឬការគំរាមរំលោភអធិបតេយ្យភាព ឯករាជ្យភាព បូរណភាពទឹកដី អព្យាក្រឹតភាព ឬឯកភាពជាតិនៃកម្ពុជា ភាគីទាំងអស់នៃកិច្ចព្រមព្រៀងនេះត្រូវតែពិគ្រោះយោបល់គ្នាភ្លាមៗ ក្នុងគោលបំណងសម្រេចគ្រប់វិធានការចាំបាច់ ដើម្បីធានាការគោរពពាក្យសន្យាទាំងនេះ និងដោះស្រាយការរំលោភបែបនេះតាមមធ្យោបាយសន្តិវិធី ។

២_វិធានការទាំងនេះមានជាអាទិ៍ ការប្តឹងទៅក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ឬការប្រើប្រាស់មធ្យោបាយដោយសន្តិវិធី ដើម្បីដោះស្រាយរាល់វិវាទដូចមានចែងក្នុងមាត្រា ៣៣ នៃធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ។

៣_ភាគីទាំងឡាយនៃកិច្ចព្រមព្រៀងនេះ អាចស្វែងរកជំនួយពីសហប្រធាន នៃសន្និសីទទីក្រុងប៉ារីស ស្តីពីកម្ពុជា (គឺប្រទេសបារាំង និងប្រទេសឥណ្ឌូនេស៊ី) ។

យើងខ្ញុំសូមរំលឹកថា កាលពីឆ្នាំ១៩៩១ មានប្រទេសជាមិត្តចំនួន ១៨ ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ។ ក្នុងចំណោមប្រទេសទាំងនោះមានមហាអំណាចទាំងអស់ក្នុងពិភពលោក (ដូចជា សហរដ្ឋអារិក ប្រទេសចិន ប្រទេសរុស្ស៊ី ប្រទេសអង់គ្លេស និងប្រទេសបារាំង) និងប្រទេសជិតខាងទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានប្រទេសថៃផងដែរ ។

សង្ខេបសេចក្តីមក កិច្ចព្រមព្រៀងទីក្រុងប៉ារីស គឺជាឧបករណ៍ច្បាប់ដ៏សំខាន់បំផុត ហើយដែលអាចមានប្រសិទ្ធភាពខ្ពស់បំផុត ដើម្បីការពារបូរណភាពទឹកដីប្រទេសកម្ពុជា និងផ្តល់យុត្តិធម៌ជូនប្រជារាស្ត្រខ្មែរ ដូចដែលឯកឧត្តម សម រង្ស៊ី បានបញ្ជាក់ជាច្រើនលើកច្រើនសារមកហើយ ។

យើងខ្ញុំសុំឲ្យរាជរដ្ឋាភិបាលបញ្ជាក់អំពីហេតុផលដែលរាជរដ្ឋាភិបាលមិនទាន់បានស្នើឲ្យប្រទេសជាហត្ថលេខីទាំងអស់នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស គោរពតាមពាក្យសន្យារបស់ខ្លួនថា មកជួយប្រទេសកម្ពុជាក្នុងគ្រាអាសន្នដូចសព្វថ្ងៃ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ យើងខ្ញុំសង្ឃឹមថា រាជរដ្ឋាភិបាលនឹងឆ្លើយនូវសំណួរខាងលើនេះឲ្យបានច្បាស់លាស់ តាមការគួរ ។

សូមសម្តេចនាយករដ្ឋមន្ត្រីទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រ អំពីយើងខ្ញុំ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១១*

**ក្រុមអ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី**

**បានឃើញ និងបញ្ជូនមក**
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
"ដើម្បីពិនិត្យ"
*ភ្នំពេញ, ថ្ងៃទី.......... ខែឧសភា ឆ្នាំ២០១១*
**ប្រធានរដ្ឋសភា**

**<u>ចម្លងជូន</u> ៖**
- សម្តេចព្រះមហាវីរក្សត្រ
- ព្រះមហាក្សត្រ
  នៃព្រះរាជាណាចក្រកម្ពុជា